ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 07 / 06 / 2017
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

E457/7

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**អង្គជំនុំជម្រះសាលាដំបូង** **សាធារណៈ / Public**

ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០១៧

**ជូនចំពោះ៖** **ភាគីទាំងអស់នៃសំណុំរឿង ០០២**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**

**កម្មវត្ថុ៖** **ការណែនាំសម្រាប់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០២**

១. ដើម្បីឱ្យសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល នៅក្នុងសំណុំរឿង ០០២/០២ ដែលនឹងចាប់ផ្តើមធ្វើពីថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០១៧ ប្រព្រឹត្តទៅដោយរលូន អង្គជំនុំជម្រះសាលាដំបូងសូមផ្តល់នូវគោលការណ៍ណែនាំដល់គ្រប់ភាគីទាំងអស់ ដូចតទៅ។

២. *ការការពារសាក្សី/សុចរិតភាពនៃកិច្ចស៊ើបសួរក្នុងសំណុំរឿង ០០៣ និង ០០៤៖* សូមរំឮកដល់ភាគីទាំងអស់អំពីអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង ឯកសារ E319/35/15 ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧ ដែលបានអនុម័តយកតាមសេចក្តីសន្និដ្ឋានរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិ នៅក្នុងអនុស្សរណៈ E319/35/14/3 ចុះថ្ងៃទី ២២ ខែ ឧសភា ឆ្នាំ ២០១៧។ អង្គជំនុំជម្រះសាលាដំបូងសូមសង្កត់ធ្ងន់ថា ការកំហិតទៅលើការសម្ងាត់ នៅតែបន្តអនុវត្តចំពោះសាក្សី និងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ ៣ នៃអនុស្សរណៈរបស់អង្គជំនុំជម្រះសាលាដំបូង។ ហេតុដូច្នេះ ភាគីទាំងអស់ត្រូវតែយោងទៅរកសាក្សីទាំងអស់នោះ ដោយ

ប្រើរហស្សនាម ក្នុងករណីដែលមានរហស្សនាម ឬ ប្រើលេខឯកសារកំណត់ហេតុស្តាប់ចម្លើយដែលពាក់ព័ន្ធ ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់ការពិភាក្សាដេញដោល។

៣. *ភស្តុតាងដែលមិនត្រូវបានទទួលយក និងសំណើសុំឱ្យពិចារណាឡើងវិញ៖* សូមរំឭកដល់ភាគីទាំងអស់ថា អង្គជំនុំជម្រះអាចពឹងផ្អែកសេចក្តីសម្រេចរបស់ខ្លួន តែទៅលើភស្តុតាងទាំងឡាយណាដែលបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងប៉ុណ្ណោះ។ អង្គជំនុំជម្រះកត់សម្គាល់ថា នៅក្នុងសារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន មេធាវីការពារក្តី នួន ជា បានស្នើសុំឱ្យអង្គជំនុំជម្រះពិចារណាឡើងវិញនូវសេចក្តីសម្រេចរបស់អង្គជំនុំជម្រះ ដែលបានបដិសេធក្នុងការទទួលយកសម្ភារៈដែលមាននៅក្នុងឧបសម្ព័ន្ធ ១ ។ អង្គជំនុំជម្រះនឹងដោះស្រាយសំណើសុំនេះនៅក្នុងពេលវេលាសមស្រប ។ ជាករណីលើកលែង និងដោយមិនបង្ករឱ្យមានព្យសនកម្មចំពោះសេចក្តីសម្រេចចុងក្រោយនោះនៅក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលខាងមុខនេះ ភាគីត្រូវបានអនុញ្ញាតឱ្យយោងទៅរកសម្ភារៈ ដែលជាផ្នែកមួយនៃសំណើសុំឱ្យពិចារណាឡើងវិញបាន ។ ភាគីណាមួយដែលជ្រើសរើសយកការយោងទៅរកសម្ភារៈបែបនេះ ក្នុងពេលធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ត្រូវបញ្ជាក់ឱ្យបានច្បាស់ដល់ភាគីដទៃទៀត ក៏ដូចជាដល់សាធារណជនផងដែរ។ នៅក្នុងបរិបទនេះ អង្គជំនុំជម្រះសាលាដំបូងសង្ឃឹមថា ភាគីទាំងអស់នឹងផ្តោតការយកចិត្តទុកដាក់ទៅលើភស្តុតាងដែលពួកគេពឹងផ្អែក នៅក្នុងសារណាបញ្ចប់ការពិភាក្សាដេញដោលរបស់ខ្លួន។ ទោះបីយ៉ាងណា ក្នុងអំឡុងសវនាការស្តាប់សេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោល ភាគីនានានឹងមិនត្រូវបានអនុញ្ញាតឱ្យយោងទៅរកសម្ភារៈដែលមិនត្រូវបានស្នើសុំឱ្យទទួលយកធ្វើជាឯកសារភស្តុតាង និងដែលមិនបានជូនដំណឹងដល់អង្គជំនុំជម្រះ ព្រមទាំងភាគីផ្សេងទៀត នោះឡើយ។

៤. *ការពិចារណាឡើងវិញ៖* អង្គជំនុំជម្រះសាលាដំបូងសូមកត់សម្គាល់ថា នៅក្នុងសារណាបិទបញ្ចប់កិច្ចពិភាក្សាដេញដោលរបស់ខ្លួន មេធាវីការពារក្តី នួន ជា បានស្នើសុំដល់អង្គជំនុំជម្រះឱ្យធ្វើការពិចារណាឡើងវិញទៅលើសំណើសុំស្តាប់សក្ខីកម្មសាក្សី និងសំណើសុំបំពេញកិច្ចស៊ើបសួរមួយចំនួនរបស់មេធាវីការពារក្តី ដែលត្រូវបានអង្គជំនុំជម្រះបដិសេធ។ អង្គជំនុំជម្រះនឹងដោះស្រាយសំណើទាំងអស់នេះ នៅក្នុងពេលវេលាសមស្រប។

៥. *ចម្លើយដែលទទួលបានដោយការធ្វើទារុណកម្ម៖* អង្គជំនុំជម្រះសូមរំឭកថា យោងតាមមាត្រា ៣២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា “ចម្លើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬ

ខាងផ្លូវចិត្តនេះ គ្មានតម្លៃជាភ័ស្តុតាងទេ"។ បន្ថែមលើនេះ ផ្អែកទៅលើមាត្រា ១៥ នៃអនុសញ្ញាប្រឆាំងការធ្វើទារុណកម្ម "ចម្លើយទាំងឡាយណាដែលត្រូវបានកំណត់ថា ទទួលបានដោយសារការធ្វើទារុណកម្ម នឹងមិនត្រូវយកមកប្រើនៅក្នុងកិច្ចដំណើរការនីតិវិធីណាមួយឡើយ លើកលែងតែយកមកប្រើប្រឆាំងបុគ្គល ដែលត្រូវបានចោទប្រកាន់ ថាបានធ្វើទារុណកម្ម ដើម្បីជាភ័ស្តុតាងថាចម្លើយនោះត្រូវបានធ្វើឡើង"។ អង្គជំនុំជម្រះសម្រេចថា ភ័ស្តុតាងដែលទទួលបានដោយការធ្វើទារុណកម្ម មិនអាចប្រើប្រាស់សម្រាប់បញ្ជាក់ការពិតនៃខ្លឹមសាររបស់ភ័ស្តុតាងនោះឡើយ។ ទោះជាបែបនេះក្ដី ព័ត៌មានបែបសត្យានុម័ត ដែលមាននៅក្នុងចម្លើយសារភាពទាំងនោះ ដូចជាកាលបរិច្ឆេទនៃការចាប់ខ្លួន ដែលមិនមែនជាផ្នែកនៃចម្លើយនោះ អាចប្រើប្រាស់បាន។ ដូចគ្នានេះ ចំពោះចំណារដែលបានចារនៅលើចម្លើយសារភាព ដោយអ្នកសួរចម្លើយ ឬ ថ្នាក់លើរបស់ពួកគេ អាចប្រើប្រាស់បាន។

៦. អង្គជំនុំជម្រះសូមរំឭកអំពីការសម្រេចរបស់ខ្លួនដែលថា ហានិភ័យពិតប្រាកដដែលកើតមានឡើង គឺថាការធ្វើទារុណកម្មត្រូវបានប្រើប្រាស់ នៅមន្ទីរសន្តិសុខ ស-២១ និងមន្ទីរសន្តិសុខដទៃទៀត ដើម្បីទទួលបានចម្លើយសារភាព (ឯកសារ E350/8 កថាខណ្ឌ ៧៩)។ ភាគីណាមួយដែលស្នើសុំប្រើប្រាស់ភ័ស្តុតាងបែបនេះ អាចជំទាស់ទៅនឹងការសម្រេចបឋមនេះបាន ជាពិសេស ដោយផ្អែកលើការបង្ហាញនូវកាលៈទេសៈជាក់លាក់ផ្សេងៗ ដែលអាចច្រានចោលនូវហានិភ័យបែបនេះ។ ដោយសារហេតុនេះហើយ ទើបនៅក្នុងសវនាការពិភាក្សា ដេញដោល ពិនិត្យភ័ស្តុតាងកន្លងមក អង្គជំនុំជម្រះមិនអនុញ្ញាតឱ្យប្រើប្រាស់ចម្លើយសារភាពដែលទទួលបានពីមន្ទីរសន្តិសុខឡើយ រាប់ទាំងមន្ទីរសន្តិសុខ ស-២១ ផងដែរ ដែលមិនបានបង្ហាញថាចម្លើយទាំងនោះមិនមែនទទួលបាន ដោយការធ្វើទារុណកម្ម។

៧. ដោយសារតែជនជាប់ចោទនៅក្នុងសំណុំរឿងនេះ ត្រូវបានចោទប្រកាន់ពីបទធ្វើទារុណកម្ម អង្គជំនុំជម្រះត្រូវតែកំណត់បទដ្ឋាននៃការបង្ហាញភ័ស្តុតាងផ្សេងពីនេះ និងខ្ពស់ជាងនេះមួយស្តីពីថាតើទារុណកម្មបានកើតឡើងដែរ ឬ ទេ។ នៅពេលពិចារណាទៅលើភ័ស្តុតាងទាំងអស់ ដែលមាននៅក្នុងដំណាក់កាលសរសេរសាលក្រម និងផ្អែកលើបទដ្ឋានសម្រាប់ការផ្តន្ទាទោសចំពោះការធ្វើទារុណកម្មនេះ ការកំណត់ជាបឋមរបស់អង្គជំនុំជម្រះអំពីហានិភ័យពិតប្រាកដទៅលើភ័ស្តុតាងបានមកដោយការធ្វើទារុណកម្មកន្លងមក អាចខុសពីសេចក្តីសន្និដ្ឋានស្ថាពររបស់ខ្លួន ។

៨. ដោយសារតែកិច្ចដំណើរការនីតិវិធីពិភាក្សា ដេញដោល ពិនិត្យលើភស្តុតាង ត្រូវបានបញ្ចប់ហើយនោះ មិនមានគ្រោះថ្នាក់ណាមួយឡើយដែលថា សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អាចទទួលរងនូវឥទ្ធិពលដោយមិនសមស្រប ដោយសារភស្តុតាងបានមកដោយការធ្វើទារុណកម្ម។ ហេតុដូច្នេះ អង្គជំនុំជម្រះអនុញ្ញាតឱ្យភាគីយោងទៅរកព័ត៌មានបែបនោះបាន ក្នុងករណីដែលយល់ឃើញថាចាំបាច់ នៅក្នុងអំឡុងពេលធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចការពិភាក្សា ដេញដោល។ ប៉ុន្តែ ភាគីត្រូវចងចាំ និងបញ្ជាក់នៅមុនពេលពិភាក្សាលើឯកសារបែបនោះថា អង្គជំនុំជម្រះបានសន្មតថា ភស្តុតាងដែលនឹងលើកយកមកពិភាក្សានេះ បានមកដោយការធ្វើទារុណកម្ម។ ការបញ្ជាក់បែបនេះគឺជាការផ្តល់នូវការជូនដំណឹងសមស្របមួយអំពីលក្ខណៈនៃភស្តុ-តាងដែលត្រូវយកមកពិភាក្សា ហើយប្រសិនបើមិនមានការបញ្ជាក់បែបនេះទេ ភាគីនានា និងសាធារណជនអាចមានការយល់ច្រឡំ។

៩. អង្គជំនុំជម្រះអនុម័តយកវិធីសាស្ត្របែបនេះ សម្រាប់ភស្តុតាងនានាដែលទទួលបានដោយការធ្វើទារុណកម្ម ដើម្បីសម្រួលដល់ការធ្វើសេចក្តីសន្និដ្ឋានបិទបញ្ចប់កិច្ចពិភាក្សាដេញដោលដោយមិនមានការរំខាន តាមដែលអាចធ្វើទៅបាន។